# សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


KKC Statement

លេខ ............................ ស.ខ.ក.ក.

# សេចក្ដីថ្លែងការណ៍

តាមប្រភពពត៌មានពីកម្ពុជាក្រោម ពីក្រុមគ្រួសាររបស់ព្រះតេជគុណ**ទឹម សាខន**នៅខេត្តតាកែវ និងពីមន្ត្រីអ្នកនាំពាក្យស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា បានឲ្យដឹងថាព្រះតេជគុណ **ទឹម សាខន**ត្រូវបានអាជ្ញាធរវៀតណាមដោះលែងកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៨ ប៉ុន្តែពុំទាន់ឃើញវត្តមានព្រះតេជគុណ**ទឹម សាខន** មកជួបជុំឪពុកចាស់ជរានិងបងប្អូន កូនក្មួយរបស់ព្រះអង្គ នៅភ្នំដីនក្នុងស្រុកគីរីវង្ស ខេត្តតាកែវ នៅឡើយទេ ។

តាមការអះអាងពីសាច់ញាតិរបស់ព្រះអង្គនៅកម្ពុជាក្រោមថាព្រះតេជគុណ**ទឹម សាខន**ក្រោយពីបានទទួលដំណឹងថា ត្រូវបានអាជ្ញាធរអាណានិគមវៀតណាមដោះលែងហើយនោះ នៅថ្ងៃទី២៨ខែមិថុនា ឆ្នាំ២០០៨ បានឃើញពួកនគរបាលវៀតណាមនាំព្រះតេជគុណ**ទឹម សាខន** ទៅជួបសួរសុខទុក្ខសាច់ញាតិ នៅក្នុងភូមិ អណ្តូងទរ ឃុំ អណ្តូងទរ(បាជុក) ស្រុក ស្វាយទង(ទ្រី តូង) ខេត្តមាត់ជ្រូក ប្រហែល៣ម៉ោង ក្នុងសម្លៀកបំពាក់ជាឃហាវាស មិនមែនគ្រងត្រៃចីវរជាព្រះភិក្ខុសង្ឃទេ ហើយមានការការពារ និងតាមដានយ៉ាងយកចិត្តទុកដាក់បំផុត ពីក្រុមនគរបាលវៀតណាមទាំងនោះ រួចហើយ ក៏នាំព្រះអង្គចេញទៅបាត់។ ព្រះតេជគុណ**ទឹម សាខន** បានទុកលិខិតមួយច្បាប់ជូនញោមប្រុសរបស់ព្រះអង្គ ដោយបានបញ្ជាក់ប្រាប់ថា អាជ្ញធរវៀតណាមនាំព្រះអង្គដើរទេសចរណ៍រយៈពេលមួយខែ។

នេះជាយុទ្ធសាស្រ្តថ្មីមួយទៀតរបស់អាជ្ញាធរអាណានិគមវៀតណាម ក្នុងការបំភន្តសាធារណមតិជាតិ-អន្តរជាតិ ក្នុងគោលបំណងអ្វីមួយ ព្រោះថាការដោះលែងនេះមានអាថ៌កំបាំងគួរឲ្យសង្ស័យ។ម្យ៉ាងទៀតជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ពីព្រោះបានកាត់ផ្តាច់មនោសញ្ចេតនារវៀងឪពុកនិងកូន បងនិងប្អូន សិស្សនិងគ្រូ ពុទ្ធបរិស័ទនិងព្រះចៅអធិការ ដែលបានទន្ទឹងរង់ចាំយ៉ាងអន្ទសារអស់រយៈពេលជាងមួយឆ្នាំមកហើយ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវយ៉ាងទទូចបំផុតដល់ :

១_រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ត្រូវតែបញ្ជូនព្រះតេជគុណ**ទឹម សាខន** មកជួបជុំគ្រួសារនៅព្រះរាជាណាចក្រកម្ពុជា ជាបន្ទាន់ដោយឥតលក្ខខណ្ឌ។

២_អង្គការជាតិ-អន្តរជាតិ និងបណ្តាអង្គទូតនានាដែលស្រឡាញ់សិទ្ធិមនុស្ស ជាពិសេសស្នងការជាន់

Appeal of the Khmer Kampuchea Krom Community:
1-The Government of Socialist Republic of Vietnam to urgently repatriate Ven. Tim Sakhorn to re-unite with his family in the Kingdom of Cambodia with no restrictions.
2-Domestic and international non-governmental organizations, and foreign embassies, especially the UN Office of the High Commissioner for Human Rights to investigate, monitor closely and assure the safety of Venerable Tim Sakhorn.


ភូមិគ្រឹះលេខ៥៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៥៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.

អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org

ខ្ពស់អង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស សូមមេត្តាជួយតាមដានករណីព្រះតេជគុណ **ទីម សាខន** ឲ្យបានដិតដល់ជាទីបំផុត ដើម្បីជួយការពារសុវត្ថិភាពព្រះអង្គ។

៣_រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាជួយអន្តរា-គមន៍ឲ្យបានខ្លាំងក្លា ដើម្បីនាំយកព្រះតេជគុណ**ទីម សាខន** មកកម្ពុជាឲ្យបានប្រញាប់បំផុត ដែលអាចធ្វើទៅបាន ព្រោះព្រះអង្គជាពលរដ្ឋខ្មែរពេញលក្ខណៈច្បាប់។ បើប្រសិន ក្នុងករណីដែលព្រះតេជ ព្រះតេជគុណ**ទីម សាខន**ចង់ស្ថិតនៅជាព្រះភិក្ខុសង្ឃភាវៈ ត្រូវតែបំបួសព្រះអង្គឡើងវិញ ដោយសា ថា ព្រះតេជគុណ**ទីម សាខន**ពុំបានប្រព្រឹត្តិល្មើសក្នុងសិក្ខាបទណាមួយនៃអាបត្តិបារាជិកនោះឡើយ។

3-The Kingdom of Cambodia's Royal Government, National Assembly, and Senate intervene to secure the safe return of Ven. Tim Sakhorn to Cambodia as this Buddhist monk is legally Khmer citizen. In circumstance that Ven. Tim Sakhorn's desire to stay as a Buddhist clergy, [authorities] must re-ordain him because he had not committed any *parajika* Buddhist offenses.

*រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨*

*តាងនាមប្រតិភូសហគមន៍ខ្មែរកម្ពុជាក្រោម*

**ថាច់ សេដ្ឋា**

*អតីតសមាជិកព្រឹទ្ធសភា*